**PTI0088**

# សម្ភាសន៍ជាមួយឈ្មោះ ប៉ុល ស៊ុន ភេទប្រុស អាយុ៥៦ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម«យោធា»

## ស្រុកកំណើតនៅភូមិពាមខ្វាវ ឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

## រស់នៅភូមិកណ្ដាល ឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់

## ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥០:៣៣

**២៨ទំព័រ**

វណ្ណៈ: ចឹងថ្ងៃហ្នឹងថ្ងៃទី២០ខែ៥ឆ្នាំ២០១១ មុននិងសម្ភាសពូ ខ្ញុំសូមនែនាំខ្លួនថាខ្ញុំមកពីខាងអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយខ្ញុំឈ្មោះ សុខ វណ្ណៈ ហើយបានមកដល់ភូមិឃុំរបស់ពូគឺចង់ដឹងរឿងរ៉ាវដែលទាក់ទងនិងរឿងប្រវត្តិសាស្ត្រ ។ កាលដែលពូធ្លាប់ឆ្លងកាត់កាលពីសម័យមុនមកបានជួបរឿងរ៉ាវអីខ្លះ ហើយមកដល់បច្ចុប្បន្នយើងតស៊ូវៃក្រោយមក៧៩ទៀតយើងវៃជាមួយវៀតណាម ។ យើងបានជួបបញ្ហាអីខ្លះ ហើយចឹងទៅខ្មែរយើងវៃគ្នាហ្នឹងមានគ្រោះថ្នាក់ទាំងសងខាងយ៉ាងម៉េចខ្លះ ហើយប្រវត្តិទាំងអស់ហ្នឹងយើងចង់ក្រងទុកឲ្យក្មេងជំនាន់ក្រោយបានដឹងបានពុដែរ ។ ចឹងបទសម្ភាសខ្ញុំជាពូតើពូអនុញ្ញាតឲ្យខ្ញុំយកទៅសរសេរចងក្រងជាសៀវភៅទុកជាប្រវត្តិសាស្ត្របានទេពូ?

ស៊ុនៈ ខ្ញុំមិនទាស់អីទេ ព្រោះអ្វីដែលជាប្រវត្តិសាស្ត្រគេចារទុកហើយទៅហើយ ។

វណ្ណៈ: បាទ ។

ស៊ុនៈ ហើយអ្វីដែលជាភាពជាក់លាក់គឺបានជួបជាមួយប្រជាពលរដ្ឋក៏ជាមួយបងប្អូនដែលរស់នៅក្នុងស្រុកភូមិ ។

វណ្ណៈ: បាទ ។

ស៊ុនៈ នៅជនបទដែលមានការឆ្លងកាត់សង្គ្រាមកម្ពុជាជាហូរហែរមកនោះណាស់ ទី១គឺសង្គ្រាមសម័យលន់ នល់ក៏ខ្ញុំបានឆ្លងកាត់ធ្វើសង្គ្រាមជាមួយអាមេរិចកាំង ។

វណ្ណៈ: បាទ ។

ស៊ុនៈ នៅកម្ពុជាមានទម្លាក់គ្រាប់បែកអា«បេ៥២»ខ្ទិចទឹកដី អង្គើទឹកអង្គើដីហ្នឹងវាហូរហែលមករហូតចឹងមក ក្រោយមកប៉ុល ពតមានអំណាចកាន់អំណាចកាន់កាប់ប្រទេសកម្ពុជារយៈពេលបីឆ្នាំ

បួនបីខែនិងម្ភៃថ្ងៃ ក្រោយមកទៀតក៏មានកងទ័ពវៀតណាមវាយចូល ហើយប៉ុល ពតបន្តមកទៀតរហូតមកដល់កងទ័ពប៉ុល ពតហ្នឹងមានការតស៊ូច្បាំងតាមដួរព្រំដែនរហូតដល់ទៅខាងក្នុងហ្នឹងហើយច្បាំងគ្នាបាញ់គ្នាសម្លាប់គ្នាហ្នឹង ស្លាប់និងទ័ពដូចគ្នាស្លាប់ទាំងប្រជាពលរដ្ឋ ។

វណ្ណៈ៖ បាទ ។

ស៊ុន៖ ដុះសំបែងឆេះភូមិក ក្រហិនហោចណាស់បើយើងគិតទៅ ។

វណ្ណៈ៖ បាទ ។

ស៊ុន៖ វេទនាណាស់ កម្ពុជាយើងរងទុក្ខមិនចេះឈប់ឈរ បើពីសម័យណាមកយើងគិតទៅយើងមានសង្គ្រាមរហូតដោយសារតែប្រទេសនៅខាងក្រៅវាចេះតែញួសញុងអុចអាលបង្កឲ្យមានលក្ខណៈទាស់ទាញបញ្ហាមិនឈប់ឈរ ។

វណ្ណៈ៖ បាទ ។

ស៊ុន៖ ហ្នឹងជាហេតុនាំឲ្យយើងគ្រោះថ្នាក់ តែមកដល់សម័យដែកដោរនេះ លោកមានគោលនយោបាយល្អដើម្បីផ្សះផ្សារបង្រួបបង្រួមជាតិបញ្ចប់សង្គ្រាមរវាងខ្មែរនិងខ្មែរ រវាងបរទេសកម្ពុជាក៏មានសុខសាន្តរហូតដល់មានការអភិវឌ្ឍន៍តាមជនបទ ទីក្រុងឲ្យនៅជិតគ្នា ។

វណ្ណៈ៖ បាទ ។

ស៊ុន៖ ហើយមានការរីកចំរើនយ៉ាងគ្រប់វិស័យ សាលារៀនមណ្ឌលសុខភាពគ្រប់ទីសទីនាំឲ្យប្រជាពលរដ្ឋយើងមានសុខភាពល្អរហូតមកដល់ថ្ងៃនេះមានមុខរបរ បង្កអាជីវកម្មកសិកម្មដំណាំដាំដុះគ្រប់ផ្នែកឲ្យប្រជាពលរដ្ឋមានការចេះដឹងគ្រប់ ពីក្មេងរហូតដល់វ័យចំណាស់ ។

វណ្ណៈ៖ បាទ ។

ស៊ុន៖ ខ្ញុំឃើញមានហេតុផលចឹង ។

វណ្ណៈ៖ ចឹងរឿងរ៉ាវទាំងអស់ហ្នឹង យើងនិងចងក្រងទុកដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងបានព្រុណាពូណាស់ ។

ស៊ុន៖ បាទ ។

វណ្ណៈ៖ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូដែរ ពូឈ្មោះអី?

ស៊ុន៖ ខ្ញុំឈ្មោះ ប៉ុល ស៊ុន ។

វណ្ណៈ៖ ពូអាយុប៉ុន្មានហើយ?

ស៊ុន៖ ខ្ញុំអាយុ៥៦ឆ្នាំ ។

វណ្ណៈ៖ ពូមានប្រពន្ធឈ្មោះ អីដែរ?

ស៊ុនៈ ឈ្មោះ សុខ ពន ។

វណ្ណៈ គាត់មានអាយុប៉ុន្មានហើយ?

ស៊ុនៈ អាយុ៩១ឆ្នាំ ។

វណ្ណៈ មានកូនចៅប៉ុន្មាននាក់សព្វថ្ងៃ?

ស៊ុនៈ មាន៥នាក់ ស្រី៣ប្រុសពីរ អះប្រុសបី ស្រីពីរ ។

វណ្ណៈ ចឹងស្រីពីរ?

ស៊ុនៈ បាទៗ!ស្រីពីរ ។

វណ្ណៈ ចឹងឪពុករបស់ពូឈ្មោះអីដែរ?

ស៊ុនៈ ឈ្មោះ ប៉ុល សារិង គាត់ស្លាប់ហើយ ។

វណ្ណៈ ចឹងម្ដាយ?

ស៊ុនៈ ម្ដាយទូច យឹម ស្លាប់ហើយ ។

វណ្ណៈ គាត់ស្លាប់ជំនាន់ណាពូ?

ស៊ុនៈ ជំនាន់ឥស្សរៈអីនោះ ។

វណ្ណៈ ជំនាន់សង្គម?

ស៊ុនៈ ជំនាន់បារាំងនោះ ។

វណ្ណៈ ស្លាប់ជំនាន់បារាំងទាំងអស់គ្នា?

ស៊ុនៈ បាទ!អត់ទេ ម្ដាយស្លាប់៧៩ហើយ គាត់ចាស់ ។

វណ្ណៈ ចឹងបងប្អូនបង្កើតពូមានប៉ុន្មាននាក់ដែរ?

ស៊ុនៈ មាន៥នាក់ដែរ ស្រី៣ប្រុស២ នៅរស់ទាំងអស់ ។

វណ្ណៈ ចុះស្រុកកំណើតពូវិញ?

ស៊ុនៈ នៅខេត្តកំពង់ស្ពឺ នៅឃុំអូរ ស្រុកភ្នំស្រួច ។

វណ្ណៈ ឥឡូវខ្ញុំចឹងដឹងភូមិមុន ភូមិ?

ស៊ុនៈ ភូមិពាមខ្វាវ ។

វណ្ណៈ ឃុំ?

ស៊ុនៈ ឃុំអូរ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

វណ្ណៈ ឥឡូវពូនៅភូមិអី?

ស៊ុនៈ ឥឡូវនៅភូមិកណ្ដាល ឃុំថ្នល់ដា ស្រុកវាលវែង ខេត្តពោធិសាត់ ។

វណ្ណៈ ចឹងកាលពូតូចពូបានរៀនសូត្រដល់ណាដែលពូ?

ស៊ុនៈ ខ្ញុំរៀនបានថ្នាក់ទី៧ បួសបាន៧ព្រះវស្សារៀនចប់ធម្មម៉ាក ។

វណ្ណៈ ចឹងខ្ញុំចង់ឲ្យពូរៀបរាប់ថា ហេតុអីបានជាពូរៀនត្រឹមថ្នាក់ទី៧ហើយទៅបួស រួចចប់ពីបួសហ្នឹង ដោយសារថាមូលហេតុអី ដោយសារសង្រ្គាមយ៉ាងម៉េចអីពូជួយរៀបរាប់មក ។

ស៊ុនៈ ពេលរៀនហ្នឹងមិនទាន់សង្រ្គាមទេ ដល់បួសទៅ៧០ហ្នឹងមានសង្រ្គាមមានរដ្ឋប្រហាររបស់លន់ នល់សម័យសីហនុហ្នឹង ។

វណ្ណៈ បាទ ។

ស៊ុនៈ បានខ្ញុំឈប់រៀបហើយឆ្នាំ៧១ខ្ញុំមកចូលជាកងទ័ព ។

វណ្ណៈ ចឹងឆ្នាំ៧១ចូលជាកងទ័ពចូលព្រៃម៉ាគី?

ស៊ុនៈ បាទ ។

វណ្ណៈ ចឹងកាលពូចូលព្រៃម៉ាគីតាមការស្ម័គ្រចិត្តឬមួយយ៉ាងម៉េចពូ?

ស៊ុនៈ យើងដូចថាមានការអំពាវនាវអីចឹងទៅ ចុះនៅជនបទចេះតែនាំគ្នាតាមគ្នាទៅមកចូលរួមកាន់ អាវុធបានតស៊ូលន់ នល់អីរដ្ឋប្រហាពីស្តេចដែនដីចឹងណាស់ ពីសម្តេចសីហនុហ្នឹងចឹងឲ្យកូនចៅ ចូលរួមធ្វើទ័ព ដើម្បីច្បាំងដើមកំចាត់គេហៅស្គីលន់ នល់គេហៅស្គី ។

វណ្ណៈ ចក្រព័ត្រអាមេរិច?

ស៊ុនៈ ហ្នឹងហើយចក្រព័ត្រអាមេរិច រដ្ឋប្រហារំលំរាជបាបន្ល័ ។

វណ្ណៈ បាទ ។

ស៊ុនៈ ដល់ចឹងពីជំនាន់នោះចាស់ទុំបុរាណយើងគឺជឿជាក់ទៅលើស្តេច យើងគោរពស្តេចដល់ចឹង យើងចេះតែនាំគ្នាចូលរួមធ្វើសង្រ្គាមច្បាំងជំនាន់ហ្នឹង ច្បាំងរហូតដល់ឆ្នាំ៧៥ ។

វណ្ណៈ តែមុនច្បាំងដល់ឆ្នាំ៧៥ហ្នឹង មុនដំបូងពូចូលនៅកន្លែងណា?

ស៊ុនៈ ខ្ញុំចូលនៅតំបន់កំពង់ស្ពឺហ្នឹងតែម្តង ។

វណ្ណៈ កងតំបន់កំពង់ស្ពឺ?

ស៊ុនៈ បាទ!គេហៅ៣៣កងតំបន់៣៣ ។

វណ្ណៈ កងតំបន់៣៣ហ្នឹងពីណាជាប្រធានតំបន់ជាគណៈតំបន់មានបែងចែកហើយនៅកាលហ្នឹង?

ស៊ុនៈ មានហើយតែយើងមិនអាចចាំគេផ្លាស់ប្តូជាប់កាលហ្នឹង ខ្ញុំនៅផ្នែកទ័ពដល់ហើយឆ្នាំ៧៥ខ្ញុំមក ការពារផ្លូវដែកនៅពោធិ៍សាត់វិញ នៅផ្នែកពោធិ៍សាត់នេះ ។

វណ្ណៈ ចឹង៧៥ការពារផ្លូវដែកវិញ?

ស៊ុនៈ បាទ!ការពារផ្លូវដែកហ្នឹងនៅតំបន់ពោធិ៍សាត់ទេ រហូតដល់យួនចូលវ៉ៃកម្ពុជាចឹងមក មកនៅអង្គភាពកងពលជើងអាកាស កងពលនៅអង្គភាពជើងអាកាស៥០២ ។

វណ្ណៈ អាហ្នឹងក្រោយ៧៩ឬយ៉ាងម៉េច?

ស៊ុនៈ ក្រោយ៧៩ ។

វណ្ណៈ ចឹងក្រោយ៧៩ហ្នឹងមានអង្គភាពជើងអាកាសទៀត?

ស៊ុនៈ ចុះពេលវ៉ៃមក ។

វណ្ណៈ ហ្នឹងវ៉ៃជាមួយវៀតណាម?

ស៊ុនៈ ហ្នឹងវ៉ៃជាមួយវៀតណាមហ្នឹង នៅកងពល៥០២រហូតមកដល់ព្រំដែននៅកងពលទី២ កងពលធំលេខ២ តាំងពីពោធិ៍សាត់រហូតដល់ថៃ ហើយនៅឆ្នាំ៨០ខ្ញុំពិការជើងឆ្នាំ៨៥ ។

វណ្ណៈ ចឹងខ្ញុំចង់សួរពូមកទៅខាងក្រោយបន្តិច មុនវ៉ៃបែកភ្នំពេញមិនចឹង ដែលយើងចូលចលនាតស៊ូតាំងពី៧០មករហូតដល់៧១-៧២-៧៣-៧៤និង៧៥ហ្នឹង ចឹងកាលហ្នឹងកំលាំងខ្មែរក្រហមមានខាងណាគេចូលរួមខ្លះ មានខាងវៀតណាមចូលរួមដែលអត់កាលហ្នឹង ហើយបានជំនួយមកពីខាងណា ដូចជាសម្ភារកាំភ្លើងការហូបចុកអី?

ស៊ុនៈ យើងនិយាយពេលវៀតណាមចូលមកនេះអន្តរជាតិផ្គត់ផ្គង់ ។

វណ្ណៈ តែខ្ញុំចង់និយាយថា នៅពេលដែលយើងវ៉ៃជាមួយទាហានលន់ នល់នោះ?

ស៊ុនៈ ជំនាន់លន់ នល់កាលហ្នឹងមានចិន ជួយឧបត្ថម្ភទាំងឡានទាំងកាំភ្លើងអីទាំងអស់ហ្នឹងគឺចិន ។

វណ្ណៈ ចឹងខ្ញុំចង់ដឹងទៀតថា កាលវ៉ៃជាមួយលន់ នល់ពូមានឃើញសកម្មភាពថា ខាងលន់ នល់ចាប់បានខ្មែរក្រហម ខាងខ្មែរក្រហមមានចាប់បានទាហានលន់ នល់ទេ ចាប់ទៅវិញទៅមកចឹងមានស្លាប់មានអីច្រើនទេពូ កាលហ្នឹង ។

ស៊ុនៈ បើនិយាយពីស្លាប់ពេលនោះមិនសូវស្លាប់ទេ ពេលបាញ់គ្នាជាមួយទាហានលន់ នល់មិនសូវមានស្លាប់កងទ័ពកុញ្ញគរទេ តែយើងមិនដឹងទេ សមរភូមិក្រោយបើខាងមុខចេះតែបាញ់រុលទៅមុខទៅអ្នកមកក្រោយចេះតែមកក្រោយមក ។

វណ្ណៈ បាទ ។

ស៊ុនៈ ចឹងកងទ័ពមិនសូវជាបានដឹងពីរឿងការស្លាប់យ៉ាងម៉េចនៅខាងក្រោយទេ ហើយចាប់បានចេះតែបញ្ជូនមកអត់មានបានទុកនៅជួរមុខទេ ។

វណ្ណៈ បាទ ។

ស៊ុនៈ ដូរទ័ពគឺអត់បានទេ ដល់ចឹងទៅរឿងស្លាប់រស់មិនសូវបានដឹងទេ មានតែចំពោះមុខឃើញទៅបាញ់ដួលរនាលអីទាំងយើងនិងគេចេះតែនៅមុខហើយ ។

វណ្ណៈ បាទ ។

ស៊ុនៈ ហើយបើត្រូវចាញ់ពីតទៅក្រោយវិញ ហើយមកដល់សង្គ្រាមជាមួយយួននេះចឹងដូចគ្នាមិនបានដឹងថា ពលរដ្ឋមានលំបាកខបសក្តទេ តែដឹងថាលើកប្រឡាយជីកទំនប់អីឃើញមានហើយ តែយើងមិនបានចូលរួមជាមួយប្រជាពលរដ្ឋទេ ។

វណ្ណៈ បាទ ។

ស៊ុនៈ យើងថាដូរទ័ពសង្គ្រាមចឹងមករហូតទល់ព្រំដែនហ្នឹងក៏ចូលមកក្នុងវិញវ៉ៃ និយាយរួមអត់បានសូវដឹងពីជីវភាពរបស់ប្រជាពលរដ្ឋជាដូរទ័ពជាទូទៅ ។

វណ្ណៈ ជាទូទៅទ័ពមិនសូវបានដឹងមែន ទ័ពនៅខាងមុខខ្ញុំធ្លាប់ជួបគាត់ច្រើនហើយគាត់មិនថាខាងក្រោយជួបការលំបាកហើយមិនបានដឹងដែរ អ្នកដែលបានដឹងលុះត្រាតែអ្នកហ្នឹងបានរត់មកខាងក្រោយបានដឹង?

ស៊ុនៈ នៅក្នុងសហករណ៍នៅក្នុងស្រុកខេត្តអីអាហ្នឹងគេដឹងហើយ ។

វណ្ណៈ បាទ ។

ស៊ុនៈ ខាងដូរទ័ពអត់ទេ ខាងខ្ញុំអីអត់ដឹងទេ ស្រាប់តែទៅមានឪពុកធំស្លាប់ដោយសារខ្មែរក្រហមដែរហ្នឹង ។

វណ្ណៈ ចឹងកាលវ៉ៃបែកឆ្នាំ៧៥ហ្នឹងពូមានបានចូលទៅដល់ភ្នំពេញដែលឬមិនបានចូលទេ?

ស៊ុនៈ ខ្ញុំអត់ទេ ខ្ញុំចូលឈរនៅលេខ៤ខ្ញុំអត់បានចូលទៅភ្នំពេញទេ ដល់ហើយខ្ញុំនៅកងខេត្តហ្នឹងនៅខេត្តកំពង់ស្ពឺ ។

វណ្ណៈ បាទ ។

ស៊ុនៈ តែដល់ពេលរៀបរយឯករាជ្យហើយនោះ បញ្ជូនអគ្គភាពខ្ញុំមួយអនុសេនាធំមកផ្លូវដែកតែម្តងហ្នឹង មកដល់ភ្នំពេញហ្នឹងគឺដេកមួយយប់ពីរយប់កន្លែងហ្នឹងហើយមកតាមផ្លូវដែកខេត្តពោធិ៍សាត់ការពារផ្លូវដែក ។

វណ្ណៈ ចឹងកាលនៅកំពង់ស្ពឺហ្នឹងតំបន់ប៉ុន្មានតំបន់៣៣?

ស៊ុនៈ តំបន់៣៣និង៣២ខាងជើងផ្លូវ៣២ខាងត្បូង៣៣ ។

វណ្ណៈ ចឹងភូមិភាគប៉ុន្មាន?

ស៊ុនៈ ភូមិភាគ៣ កាលជំនាន់នោះគេហៅភូមិភាគនិរតី ។

វណ្ណៈ ចឹងភូមិភាគនិរតីដែរ?

ស៊ុនៈ បាទ!តា ម៉ុក តែបើនិយាយពីឥឡូវភូមិភាគ៣ ជំនាន់ខ្ញុំភូមិភាគនិរតីហើយទៅខាងផ្នែកកោះកុងនៅនេះទៅគេហៅបស្ចឹម ។

វណ្ណៈ ចឹងកាលដែលដឹកនាំចលនាវៃចូលឆ្នាំ៧៥ហ្នឹងប្រធានកងពលពូមានស្គាល់ទេ?

ស៊ុនៈ អត់ទេ ។

វណ្ណៈ កាលពូនៅខាងកំពង់ស្ពឺ?

ស៊ុនៈ អាហ្នឹងកងថ្នាក់ភូមិភាគហើយខ្ញុំកងតំបន់អត់សូវដឹងទេ ។

វណ្ណៈ ចឹងប្រធានតំបន់ប្រធានអី?

ស៊ុនៈ ប្រធានតំបន់ក៏ភ្លេចបាត់ដែលហ្នឹងខ្ញុំមិនសូវចាំ ។

វណ្ណៈ ចឹងកាលពូវៃបែកឆ្នាំ៧៥ហ្នឹងហើយប្រហែលជាឆ្នាំណាឆ្នាំ៧៥ហ្នឹងដដែលគេឲ្យមកការពារផ្លូវដែកពោធិ៍សាត់?

ស៊ុនៈ បាទ ។

វណ្ណៈ កាលពូមកមានគ្នាប៉ុន្មាននាក់?

ស៊ុនៈ មក១០០ជាងនាក់មួយអនុសេនាធំ ខ្ទង់៨០ឬ១០០ជាងតែមិនមែន៨០ទេមានតែ១០០ជាងមកការពារផ្លូវដែកចាប់ពីពោធិ៍សាត់មករហូតកំពង់ឆ្នាំងអាណូរីពីរបីគ្រឿងហ្នឹងទាំងយប់ទាំងថ្ងៃ ។

វណ្ណៈ ចឹងកាលនៅការពារផ្លូវដែកហ្នឹងកាលហ្នឹងគេមានបែងចែកពីណាប្រធានអីទេ?

ស៊ុនៈ កាលហ្នឹងខ្ញុំការពារផ្លូវដែកហ្នឹងបងប្រាជ ចាន់មួយអីចាន់មិនដឹងទេ គាត់សខ្ញុំវាភ្លេចទៅគាត់គ្រប់គ្រងថ្នាក់តំបន់ហ្នឹងពីពោធិ៍សាត់ទៅដល់ភ្នំពេញហ្នឹងគាត់ហើយពីពោធិ៍សាត់ទៅបាត់ដំបងឈ្មោះ ពេជ្រ និល ដូចជាប្រាជ ចាន់ មិនដឹងថាស្អីចាន់គាត់ភ្លេចដែរ ។

វណ្ណៈ ចឹងឈ្មោះ ចាន់?

ស៊ុនៈ ឈ្មោះ ចាន់ ។

វណ្ណៈ គាត់មានឋានៈអីដែរ?

ស៊ុនៈ មានឋានៈភូមិភាគផ្លូវដែក អះ!តំបន់ផ្លូវដែក ។

វណ្ណៈ ពូនៅផ្លូវដែកហ្នឹងខ្ញុំចង់ឲ្យពូរៀបរាប់ថា ពូបានឃើញបើអីខ្លះដែលអត់ កាលជំនាន់៧៥ដល់៧៩ហ្នឹង?

ស៊ុនៈ យើងមិនបានដឹងរឿងគេដឹកជារឿងមួយផ្នែកគេផ្សេងទៀត ។

វណ្ណៈៈ បាទ ។

ស៊ុនៈ យើងការពារយើងគ្រាន់តែការពារអត់មានបានទៅឆែកឆេរដើម្បីពិនិត្យលើទូហ្នឹងគេដឹងអីខ្លះ ពីណាចូលទៅណាដឹងថាមានចេញចូលតែយើងមិនដឹងថាដឹកអីទេ ។

វណ្ណៈៈ ចឹងពូនៅការពារហ្នឹងរហូតដល់ដាច់វៀតណាមហ្នឹងតែម្តង?

ស៊ុនៈ ដល់៧៩ហ្នឹងតែម្តងដល់វៀតណាមមកតែម្តង ។

វណ្ណៈៈ ចឹងកន្លែងពូនៅក្នុងសម័យខ្មែរក្រហម ថ្វីត្បិតថាពូបានចូលបំរើបានកាន់កាំភ្លើងវ៉ៃឈ្នះដណ្តើមពីលន់ នល់បានបានមែនក៏ប៉ុន្តែក្រោយមក ដូចថាខ្មែរក្រហមមានគោលការណ៍ដំបូងសម្លាប់ពួកមូលធនសម្លាប់ពួកមន្ត្រីរាជការលន់ នល់អីចឹងដែលពាក់ព័ន្ធតែក្រោយមកទៀត៧៧-៧៨នេះខ្មែរក្រហមចាប់ផ្តើមសម្លាប់គ្នាឯងទៀត ដូចជាចាប់មេខ្មែរក្រហមដែរ?

ស៊ុនៈ អត់ដឹងដូរទ័ពអត់មាន ។

វណ្ណៈៈ ចឹងមេទ័ពនៅកាន់ប្រធានភូមិភាគពូហ្នឹង គាចាន់នៅរស់ដល់រាល់ថ្ងៃអត់មានពីណាចាប់ខ្លួនគាត់ទេ?

ស៊ុនៈ មិនដឹងជាគាត់រត់ទៅណា ពេលដែលខ្ញុំមកព្រំដែនមិនដឹងជាគាត់ទៅណា បែកគ្នាបាត់ទៅ ។

វណ្ណៈៈ ចឹងបែកគ្នា?

ស៊ុនៈ បាទ! ព្រោះគាត់នៅគ្រប់គ្រងទ័ពទេ គាត់គ្រប់គ្រងផ្លូវដែកហ្នឹងដូចថាមេរួមដល់អង្គភាពខ្ញុំស្គាល់មិត្តភក្តិចឹងខ្ញុំបំបែកខ្លួនចូលមក៥០២ ។

វណ្ណៈៈ ចឹងបែក៧៥ដល់៧៩ការពារផ្លូវដែកពូមានឋានៈអីដែលកាលហ្នឹង?

ស៊ុនៈ ខ្ញុំជាប្រធានអនុសេនាធំ ។

វណ្ណៈៈ ចឹងអនុសេនាធំមានគ្នាប៉ុន្មាននាក់ពូ?

ស៊ុនៈ មាន១០០នាក់ជាង១២០ទៅ១៣០ ។

វណ្ណៈៈ ចឹងអាហារហូបចុកនៅកន្លែងពូហ្នឹងគ្រប់គ្រាន់?

ស៊ុនៈ គ្រប់គ្រាន់អត់មានបញ្ហាអីទេ ។

វណ្ណៈៈ ចឹងនៅកន្លែងហ្នឹងកូនចៅពូមានខុសសីលធម៌ខុសវិន័យអង្គការត្រូវគេចាប់ខ្លួនមានទេពូ?

ស៊ុនៈ អត់ដូចជាអត់មាន ។

វណ្ណៈៈ ចឹងអត់មាន?

ស៊ុនៈ អត់មានសំខាន់ចេះតាមខ្ញុំមើលនៅតាមសហករណ៍ក៏ដោយ សំខាន់គឺអ្នកគ្រប់គ្រងចេះដោះស្រាយព្រោះក្នុងគោលការណ៍នយោបាយរបស់ប៉ុល ពតគឺប្រាប់ថាមាគ៌ាខ្ញុំឡើងប្រជុំនៅភ្នំ

ពេញស្តាតអីគឺថាមួយថ្ងៃបីពេល បីថ្ងៃបន្ថែមម្តងតែអ្នកដឹកនាំទេ ដែលធ្វើឲ្យខុសខ្ញុំឃើញដាក់លាក់ខ្ញុំថ្នាក់ជាយុវកកបក្សជនដែលហ្នឹង ។

វណ្ណៈ: បាទ ។

ស៊ុនៈ ខ្ញុំឡើងទៅប្រជុំគោលការណ៍មានច្បាស់លាស់ចឹង ទូទៅគ្រប់ភូមិភាគចឹងគ្រប់តំបន់គឺបីថ្ងៃបាយមួយថ្ងៃ១២ថ្នាំងក្នុងមួយនាក់មួយឆ្នាំ ហើយមួយថ្ងៃឲ្យហូបបីពេលនិងបីថ្ងៃបន្ថែមម្តងនេះជាគោលការណ៍រួម តែអ្នកដែលគេយកមកកែឆ្នៃតាមសហករណ៍តាមខេត្តអីខ្ញុំអត់ដឹង បើដូរទ័ពយើងហូបចឹងគ្រប់គ្រាន់អត់មានខ្វះខាតអីទេ ។

វណ្ណៈ: ពីណាជាអ្នកនិយាយចឹង?

ស៊ុនៈ នេះជា សំដីនួន ជា ពេលនោះប៉ុល ពតក៏ខ្ញុំមិនដែលស្គាល់ឃើញមុខគាត់ដែលណានួន ជាតែម្តង ខ្ញុំស្គាល់តែខៀវ សំផននិងនួន ជាទេ បើនិយាយពីពេលនោះប៉ុល ពតមិនដែលឮឈ្មោះទៀតផង ។

វណ្ណៈ: ចឹងអៀង សារីអី?

ស៊ុនៈ អៀង សារីក៏មិនដែលបានជួបដែរ ស្គាល់តែខៀវ សំផននិងនួន ជាបានជួបផ្ទាល់តាំងពីហ្នឹងមក ក្រៅពីហ្នឹងគ្រាន់តែឮឈ្មោះទេ ផ្នែកនេះផ្នែកនោះអីយើងមិនសូវបានចាប់អារម្មណ៍ផងជំនាន់ហ្នឹង ដឹងថាការងារយើងកំរិតណាយើងធ្វើប៉ុណ្ណឹង ដោះស្រាយជីវភាពទ័ពយ៉ាងម៉េចហូបយ៉ាងម៉េចពលកម្មយ៉ាងម៉េច ជួយស្ទូងដកចុះជួយប្រជាពលរដ្ឋអីខ្លះចឹងទៅ ។

វណ្ណៈ: បាទ!ដូចជាពូមានប្រសាសន៍ចឹង ថាថ្នាក់លើបានណែនាំឲ្យហូបក្នុងមួយថ្ងៃបីពេលចឹងមានបន្ថែមអីចឹង ចឹងពូគិតថាថ្នាក់ក្រោមក្បត់ថ្នាក់លើឬមួយយ៉ាងម៉េចដែលពូ?

ស៊ុនៈ បើទស្សនៈខ្ញុំគឺថ្នាក់ក្រោមដូចជាថ្នាក់សហករណ៍អីវាចេះ ខ្ញុំពិនិត្យឃើញឧទាហរណ៍ថាមនុស្សកំពង់ធ្វើស្រែចំការអត់យល់ពីច្បាប់ទំលាប់ការងារអីសោះណាស់ ហើយល្ងង់ខ្លៅទៀតដល់ចឹងឲ្យមកធ្វើជាចៅហ្វាយស្រុកឲ្យមកធ្វើជាប្រធានសហករណ៍ ដល់ចឹងមនុស្សប្រភេទហ្នឹងល្ងង់ខ្លៅដល់ល្ងង់ខ្លៅទី១ប្រាប់ប៉ុណ្ណាធ្វើប៉ុណ្ណឹងឬក៏ធ្វើមិនអស់ទេ ទី២ដោយបានមានអំណាចយកអំណាចនេះទៅរំលោភប៉ះពាល់ដល់ប្រជាពលរដ្ឋ ។

វណ្ណៈ: បាទ ។

ស៊ុនៈ ដូចថាយើងនិយាយទូទៅ សាមញ្ញថានិយាយដើមនិយាយបរិហាពីអ្នកតូចទាបឬក៏អ្នកអត់ដឹងមានទូនាទីអីនិយាយប៉ះពាល់ជាចៅហ្វាយស្រុកប៉ះគេជាប្រធានសហករណ៍អីចឹងទៅមានពួកអុចអាលមួយចំនួនទៀត ដែលវាខ្សិបខ្សៀវរាយការណ៍ពួកយកការណ៍យប់ថ្ងៃនោះណាស់ ។

វណ្ណៈ បាទ ។

ស៊ុនៈ អាហ្នឹងជាអ្នកបង្កបញ្ហាដល់ចឹងទៅអ្នកមានអំណាចអត់យល់ពីច្បាប់ទំលាប់យល់ពីនយោបាយ មាគ៌ាអីវាទៅបង្កបញ្ហាទៅសម្លាប់មនុស្សដោយអត់មានបាច់សម្រេចកាត់ក្ដីអីទេ វាអត់មាន ។

វណ្ណៈ បាទ ។

ស៊ុនៈ ខ្ញុំជាប្រធានសហករណ៍ខ្ញុំចង់សម្លាប់អ្នកណាគឺសម្លាប់បាន ។

វណ្ណៈ គ្មានតុលាការ?

ស៊ុនៈ គ្មានតុលាការកាត់ទោស ហ្នឹងខ្ញុំឃើញច្បាស់ចឹងតែម្ដង ហើយលួចឆក់ឬសីលធម៌អីខ្លួនឯង សម្រេចខ្លួនឯងតែម្ដងអត់មានចាំបាច់ពីណាមកសម្រេច ។ ហើយអ្នកដែលគេចេះដឹងនៅក្នុង សង្គមហ្នឹងគេចេះយល់យោគចេះអធ្យាស្រ័យចេះដោះស្រាយបញ្ហាទៅវាអត់អីទេ ។ តែដល់ អ្នកខ្លៅហ្នឹងគេឲ្យប៉ុន្មានធ្វើប៉ុណ្ណឹង គេឲ្យម៉េចធ្វើចឹងហើយកំហឹងរបស់ខ្លួនមានអំណាចផងចេះតែ បង្កបញ្ហាឲ្យគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋទៅអត់មានពីណាដឹងអី ។

វណ្ណៈ ចឹងកាលជំនាន់បីឆ្នាំហ្នឹង ពូជឿថាមានប្រជាជនអត់បាយមែនសម្លាប់មនុស្សមែនពូជឿទេ?

ស៊ុនៈ ជឿ ខ្ញុំជឿមានពេលខ្លះខ្ញុំដើរទៅក្រៅចេញពីផ្លូវដែកអីទៅចូលដើរទៅលេងតាមសហករណ៍អី ឃើញប្រជាពលរដ្ឋអត់មានបាយមែនតើ ។

វណ្ណៈ បាទ ។

ស៊ុនៈ ហើយយើងគិតថា តើមាគ៌ានយោបាយទូទាំងប្រទេសដែលតម្រូវឲ្យធ្វើរបៀបហ្នឹងដូចទ័ពដូច ប្រជាជនដូចគ្នាចឹង តែយ៉ាងម៉េចបានទៅជាចឹង យើងក៏មិនដឹងជាថាយ៉ាងម៉េច ជាហេតុផល ដែលខ្ញុំចុះមកអន្ទងធ្នង់អីខ្ញុំនៅម៉ាដូរខាងហ្នឹង ។ ឃើញប្រជាពលរដ្ឋដើរមកក្មេងៗលួចឆក់ទៅ កន្ទែងខ្ញុំអីលួចបាយក្ដាំងអីចឹងទៅណាស់ ។

វណ្ណៈ បាទ ។

ស៊ុនៈ ដល់ចឹងខ្ញុំគិតថា ការហេវហ្វានគិតរហូតដល់មានការក្នុងថ្ងៃមួយនោះឃើញគ្រួសារមួយកូន ស្លាប់យកសាច់កូនហូប ។

វណ្ណៈ បាទ ។

ស៊ុនៈ តែខ្ញុំមិនបានឃើញនិងភ្នែកទេ គ្រាន់តែទ័ពនៅជាមួយខ្ញុំមករាយការណ៍ខ្ញុំគិតថា រឿងនេះកើត ធំហើយកើតបញ្ហាហើយ ។

វណ្ណៈ បាទ ។

ស៊ុនៈ ព្រោះខ្ញុំគិតថា មនុស្សទៅហូបមនុស្សទី១ ទី២ការអត់ឃ្លានចឹងខ្ញុំគិតថាអ្នកដឹកនាំពេលហ្នឹងគឺមានបញ្ហាហើយ ។

វណ្ណៈ បាទ ។

ស៊ុនៈ អានេះអារម្មណ៍ខ្ញុំគិតខ្ញុំចេះតែប្រយត្ន័ខ្លួនឯង ធ្វើយ៉ាងម៉េចឲ្យគង់វង់ជីវិតខ្លួនឯង ព្រោះខ្ញុំបានឆ្លងកាត់ខ្ញុំបានរៀនសូត្រចេះដឹងអីខ្លះក្នុងផ្លូវធម៌ផ្លូវលោកអីចឹង ។

វណ្ណៈ បាទ ។

ស៊ុនៈ ខ្ញុំចេះបទបែនបៀបក្នុងសង្គមយើងមិនធំមិនតូចចេះសម្របសំរួលចេះដោះស្រាយបន្តបន្ទាប់ឲ្យមានហូបចុកគ្រប់គ្រាន់ប្រើប្រាស់ការងារ ចាត់ចែងការងារសមហេតុផលរហូតដល់ព្រំដែនខ្ញុំមានសេចក្ដីសុខរហូត ។

វណ្ណៈ បាទ ។

ស៊ុនៈ ចេះមានទេវតាមានអ្នកតាភ្នំជួយខ្ញុំថែរក្សាខ្ញុំរហូតលុះដល់ព្រំដែន ។

វណ្ណៈ បាទ ។

ស៊ុនៈ មកដល់ព្រំដែនហើយអង្គភាពខ្ញុំមកធ្វើមេក្រុមកងពិសេសវិញពីអនុសេនាធំខ្ញុំមកធ្វើកងពិសេសរហូតដល់ខ្ញុំកាន់វរៈសេនាតូចផ្លូវ៥៦អីកងទ័ពរស់នៅជាមួយខ្ញុំហូរហែរ ។

វណ្ណៈ បាទ ។

ស៊ុនៈ ពេលដាច់ជើងហើយខ្ញុំមកគ្រប់គ្រងជនពិការរាប់ពាន់នាក់ គេគោរពស្រឡាញ់ខ្ញុំរហូតដល់សមាហរណ៍កម្មខ្ញុំធ្វើជាមេឃុំនៅថ្មដា ។

វណ្ណៈ បាទ ។

ស៊ុនៈ គេនៅតែគោរពស្រឡាញ់ដោយសាទឹកចិត្តយើងនយោបាយយើងស្មារតីយើងចេះជួយគ្នាចេះសាមគ្គីគ្នាចេះដោះស្រាយបញ្ហាសំខាន់គឺចំណេះដឹងតែម្ដង ។

វណ្ណៈ បាទ ។

ស៊ុនៈ ចឹងបានខ្ញុំមកដល់រាល់ថ្ងៃខិតខំឲ្យកូនរៀនទោះបីខ្វះខាតជីវភាពយ៉ាងណាក៏ដោយ រៀនដល់បាក់ឌុបអីប្រឡងបាក់ឌុបឆ្នាំនេះ ហើយប្រឡងជាប់បណ្ដុះបណ្ដាលឲ្យវារៀនទេ គឺអ៊ីដែលល្ងង់ខ្លៅពិបាកអប់រំពិបាកនិយាយគ្នា ។

វណ្ណៈ បាទ ។

ស៊ុនៈ ដូចថាយល់យ៉ាងម៉េចទៅក៏រិតប៉ុណ្ណាបានប៉ុណ្ណឹងយើងជួយបន្ថែមទៀតក៏អត់ដែរ អត់ប្រយោជន៍ដែរ ។

វណ្ណៈ   បាទ ។

ស៊ុនៈ   នោះជាហេតុផលដែលខ្ញុំគិតការចេះដឹង ។

វណ្ណៈ   ចឹងកាលពូនៅការពារខេត្តពោធិ៍សាត់ហ្នឹងពូនៅម្តុំណា?

ស៊ុនៈ   ខ្ញុំឈរនៅកន្លែងដំណាកហ្នឹងតែម្តងនៅប៉ុស្តិ៍ដំណាកហ្នឹង ។

វណ្ណៈ   ចឹងផ្លូវដែកដំណាកចឹង?

ស៊ុនៈ   បំណាក់ៗលាតសន្ធឹង១០គីឡូម៉ែត្រផ្លូវដែក   ១០គីឡូម៉ែត្រចឹងទៅមុខសញ្ញាមួយអនុសេនាធំទៅ១០គីឡូម៉ែត្រទៀតមុខសញ្ញាមួយចឹងទៅ ។

វណ្ណៈ   ចឹងនៅហ្នឹងរហូតពូ?

ស៊ុនៈ   នៅរហូតដល់៧៩ហ្នឹងតែម្តង ។

វណ្ណៈ   ចឹងខ្ញុំចង់បន្តរឿងរ៉ាវដែលពូបានឃើញប្រជាជនអត់បាយអត់ឃ្លានអីចឹង   ពូគិតថាថ្នាក់លើពូបានទៅប្រជុំ ចឹងកាលហ្នឹងពូទៅប្រជុំបានប៉ុន្មានដងដែលទៅភ្នំពេញ?

ស៊ុនៈ   ក្នុងមួយឆ្នាំឡើងប្រជុំមួយដង ។

វណ្ណៈ   ចឹងបីឆ្នាំបានប្រជុំតែបីដង?

ស៊ុនៈ   បានតែបីដង តែយើងគិតថា ការប្រជុំជាមាគ៌ារបស់ប៉ុល ពតដែលចង្អុលប្រើឲ្យធ្វើហ្នឹងគឺបើមានការកែតម្រូវណាមួយត្រូវហៅកម្មាភិបាលថ្នាក់ក្រោមៗទៅប្រជុំឬថ្នាក់លើមកប្រជុំនៅថ្នាក់ក្រោម ។

វណ្ណៈ   បាទ ។

ស៊ុនៈ   តែមិនសូវមានទេ ឲ្យចេញពីយុវកកបក្សទៅគឺសុទ្ធតែឡើងប្រជុំដល់ភ្នំពេញហើយ ។

វណ្ណៈ   ចឹងពេលប្រជុំម្តងៗប្រជុំនៅស្តាតមែន?

ស៊ុនៈ   បាទ!ប្រជុំនៅស្តាត ។

វណ្ណៈ   មានមនុស្សច្រើនទេ?

ស៊ុនៈ   មានមនុស្សរាប់ពាន់នាក់  ហើយចេះតែសម្ងឹងឃើញបញ្ហាសីលធម៌ក៏ជាការសម្លាប់  ការលួចឆក់ជាចំណីអាហារហើបចុកក៏ជាការសម្លាប់  ខ្ញុំចេះតែឆ្ងល់គិតថា  ដូចជាមាគ៌ានយោបាយហ្នឹងអត់មានថាចឹង  អត់មាននិយាយចឹងទេ ។

វណ្ណៈ   បាទ ។

ស៊ុនៈ   តែមិនដឹងជាមកពីអីវាអត់យល់ដល់ហ្នឹង ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរពូទៀត ពូដូចថាកំហុសទាំងអស់ហ្នឹងពូគិតថាមកពីថ្នាក់លើមានការធ្វេសប្រហែស ឬក៏ថ្នាក់លើគាត់និយាយមកចឹងមែន ក៏ប៉ុន្តែចិត្តគាត់មានគំនិតអីផ្សេងបានធ្វើជាជនរងគ្រោះឬមួយយ៉ាងម៉េចពូ?

ស៊ិនៈ វាចែកជាពីរតាមខ្ញុំគិត ទី១ដោយការធ្វើប្រហែសដោយជឿថ្នាក់ក្រោមហួសហេតុដូចថាយកការតស៊ូប៉ុន្មានឆ្នាំមកដែលឈ្នះភ្នំពេញទាំងមូលលន់ នល់ទាំងមូលហ្នឹង ។

វណ្ណៈ៖ បាទ ។

ស៊ិនៈ ដល់ចឹងទៅឃើញការជឿជាក់ទៅលើគណៈតំបន់គណៈស្រុកគណៈអីកងទ័ពអីហ្នឹង យកការជឿជាក់លើកងទ័ពហ្នឹង មានភ្នាក់ងារបជ្រៀបចូលទៅសហករណ៍ខេត្តស្រុកនោះណាស់ ។

វណ្ណៈ៖ បាទ ។

ស៊ិនៈ ដល់ចឹងជឿទៅអ្វីដែលថ្នាក់ក្រោមធ្វើដូចជាអត់បានធ្វើខ្ញុំមើល ។

វណ្ណៈ៖ បាទ ។

ស៊ិនៈ ដូចជាអត់បានដឹងសោះ ប៉ុន្តែជាអ្វីជាគំនិតវិទ្យាសាស្ត្រនយោបាយយ៉ាងម៉េចខ្ញុំអត់ដឹងទេ ខ្ញុំតែមើលគោលការណ៍មាគ៌ានយោបាយដាក់គោលការណ៍ឲ្យយើងធ្វើហើយនិងអ្នកខាងក្រោមធ្វើខុសគ្នាហើយខុសគ្នាហើយអត់មានពីណាមកឈឺឆ្អាលគិតគូ ។

វណ្ណៈ៖ បាទ ។

ស៊ិនៈ នេះជាបញ្ហាដែលខ្ញុំបានគិត ហើយដឹងថាបញ្ហានេះមានការរីករាលដាលកាន់តែខ្លាំងហើយ ។

វណ្ណៈ៖ ចឹងពូគិតចេះ យើងឥឡូវយើងមិនដឹងថាតុលាការគេកាត់ហើយប៉ុន្តែយើងគ្រាន់តែចង់ដឹងសខ្មៅថាមកពីមូលហេតុអី សូម្បីតែខ្ញុំជាអ្នកធ្វើការខាងស្រាវជ្រាវក៏ខ្ញុំនៅតែឆ្ងល់ ហើយពីនិងប្រជាជនដ៏ទៃទៀតអ្នកតស៊ូមួយចំនួនទៀតគាត់ គាត់អត់បានជួបការលំបាកដូចថាមេដឹកនាំគាត់អីចឹងយើងជឿចឹងទាំងអស់គ្នា ព្រោះមិនមែនជាកំហុសរបស់គាត់ទេ ព្រោះគាត់ឃើញល្អចឹងមែន តែភាពដឹកនាំដែលនាំឲ្យប្រជាជនស្លាប់ច្រើនហ្នឹង យើងក៏មិនទាន់បានដឹងទាំងអស់គ្នាណាពូ?

ស៊ិនៈ បាទ ។

វណ្ណៈ៖ តែគ្រាន់តែពូគិតលេងទាំងពូទាំងខ្ញុំវាគ្មានបញ្ហាអីទេ ពូគិតថាថ្នាក់ដឹកនាំនេះទី១ពូគិតមើលយកអ្នកដែលមិនចេះដឹងទៅឲ្យដឹកនាំប្រជាជន ទី២ផ្នែកវិជ្ជាពេទ្យពូគេរៀនទាល់ចប់ថ្នាក់អី រៀនអស់ច្រើនណាស់បានគេឲ្យធ្វើពេទ្យ តែថ្នាក់ដឹកនាំខ្មែរក្រហមមិនបានគិតគូចឹងទេ គឺយកក្មេងអាយុ១២ទៅ១៣ឆ្នាំ១៤ឆ្នាំឲ្យទៅធ្វើពេទ្យព្យាបាលមនុស្ស ឲ្យរៀនពេទ្យដែលមិនបានចេះ

អក្សរសោះ ហើយចំណាំថ្នាំ ចឹងពូគិតថា តើគេគិតក្នុងន័យថាសម្រាប់ខ្មែរឬក៏គេចង់ធ្វើយ៉ាងម៉េចរឿងនយោបាយហ្នឹង គ្រាន់ពីគិតថាវាមានន័យបន្តប់ក្នុងហ្នឹងដែលឬក៏យ៉ាងម៉េច ខ្ញុំចង់ដឹងពីយោបល់ពូវិញ?

ស៊ុនៈ បើយើងមើលប្រវត្តិសាស្រ្តនិងយុត្តិសាស្រ្តកម្ពុជាយើង ចុះធម្មតាប្រទេសមួយទៅប្រទេសមួយសង្គមមួយទៅសង្គមមួយថ្នាក់ដឹកនាំមួយទៅថ្នាក់ដឹកនាំមួយតែងតែមានទំនាស់ ដូចយើងមានប្រពន្ធគ្រួសារមួយតែងមានទំនាស់ ។

វណ្ណៈ៖ បាទ ។

ស៊ុនៈ ទំរាំតែភូមិមួយទៅភូមិមួយពីស្រុកមួយទៅស្រុកមួយ ថ្នាក់តំបន់ខេត្តក្រុងចឹងណាស់ប្រទេសមួយវាតែងតែមានការជ្រៀតជ្រែកពីអ្នកដ៏ទៃ ។

វណ្ណៈ៖ បាទ ។

ស៊ុនៈ បើអត់ទេ យើងគិតថា បើម្នាក់ៗចេះគោរពអ្នកដឹកនាំចេះគោរពមេស្មើគ្នាទូទៅសេចក្តីសុខហ្នឹងក៏វាមានដែរ ហើយគ្រួសារមួយចឹងដែលបើចេះសាមគ្គីគ្នាចេះយល់យោគគ្នាក៏ក្រុមគ្រួសារមួយមានសេចក្តីសុខដែរ បើគ្មានអ្នកដ៏ទៃមកជ្រៀតជ្រែក ឧទាហរណ៍ប្រពន្ធយើងផិតប្តីទាល់តែមានអ្នកដ៏ទៃមកឱ្យបខ្សៀវបញ្ហាចេះចុះទៅបានវាផិតប្តី ។

វណ្ណៈ៖ បាទ ។

ស៊ុនៈ អាហ្នឹងវាចឹងដែលរឿងខ្មែរក៏ចឹងដែរ បើគ្មានបរទេសមកជ្រៀតជ្រែកទេ ខ្ញុំជឿថាអត់មានបញ្ហា មកដល់ពេលនេះដែលសម្តេចនាយករដ្ឋមន្ត្រីលោកដែកដោ លោកយល់ ។

វណ្ណៈ៖ បាទ ។

ស៊ុនៈ យល់ពីអ្វីៗដែលប្រវត្តិសាស្រ្តកម្ពុជា តាំងពីថៃខ្មែរមានជំលោះអីស្រាយជ្រាវទាំងអស់យកមកប្រមូលម៉ុំគ្នាអ្នកនយោបាយអ្នកចេះដឹងទាំងអស់យកមកពិភាក្សារកការរីកចំរើនទៅឃើញទេ បញ្ហាត្រង់ណាៗជ្រៀតជ្រែកគឺនយោបាយបក្សនេះបក្សនោះអីវាលំបាកដែរ បើយើងឯកភាពគ្នាយល់ព្រមគ្នារួមដៃគ្នា តែជំនាន់នោះយើងគិត ហើយយើងមើលទៅហេតុផល ខ្ញុំមើលសៀវភៅច្រើនដែរ ។

វណ្ណៈ៖ បាទ ។

ស៊ុនៈ ដូចជាឧទាហរណ៍សម័យសម្តេចសីហនុ ហាន់ណូយវៃព្រៃនគរអី ដើម្បីចែកកម្ពុជាក្រោមជាពីរអីក៏មានដឹងជាប្រវត្តិសាស្រ្តខ្លះដែរ ។

វណ្ណៈ៖ បាទ ។

ស៊ុនៈ ដល់ចឹងទៅមិនឲ្យកងទ័ពវៀតណាមហាន់ណូយហ្នឹង ពីសែនប្រាំម៉ឺននាក់ទៅវៃព្រៃនគរ ដោយវៃដើងទឹកមិនបាន ដល់វៃមិនបានចឹងចូលវៃហើយឈ្នះ ឈ្នះហើយយើងក៏ឈ្នះក្រោយពេលហូរ ឈាមជាច្រើន លេបថ្នាំសម្លាប់ខ្លួនបញ្ចប់ឯកសារហ្នឹង ។

វណ្ណៈ បាទ ។

ស៊ុនៈ បញ្ហាទាំងអស់នេះបើយើងមើលទៅវាពិបាកនិយាយណាស់ រឿងនយោបាយ ។

វណ្ណៈ បាទ ។

ស៊ុនៈ តែបើយើងដឹង យើងចេះតែដឹងខ្លះៗហើយប្រវត្តិសាស្ត្រកម្ពុជាយើង អាមេរិចកាំងមានគោលការណ៍អី ។

វណ្ណៈ បាទ ។

ស៊ុនៈ យើងដឹងហើយបានហ៊ានយក«បេ៥២»ពោយដូចជានំបញ្ចុក ។

វណ្ណៈ បាទ ។

ស៊ុនៈ សុទ្ធតែមានយុត្តិសាស្ត្រហើយ ចិនមានគោលការណ៍បានជាប្រឹងជួយ ។

វណ្ណៈ បាទ ។

ស៊ុនៈ អាហ្នឹងយើងត្រូវមើលទាំងអស់ៗទៅបានយើងដឹង ហើយនាំឲ្យទាំងអស់ហ្នឹងជ្រៀតជ្រែកបានជាបញ្ហាខ្មែរយើងវាសាមគ្គីគ្នាមិនបាន សេចក្តីសុខគ្មាន ចឹងមានតែបញ្ហារហូតដូចជាអូនឯងចឹងនៅសុខៗគេទម្លាក់ចេញពីតំណែង ឧទាហរណ៍មិនក្តៅក្រហាយមិនជាមូលហេតុអី មានពីណាមកប្រាប់ថា ប្អូនឯងចេះៗខ្ញុំនេះអាចមានអំណាចចេះតែបំផ្លាញគេ ។

វណ្ណៈ បាទ ។

ស៊ុនៈ ហើយគេជាអ្នកបាត់បង់អំណាចគេចេះតែតស៊ូទៅ ដល់ចឹងការមានជំលោះវាអត់ឈប់ឈរទេ អាហ្នឹងយើងប្រៀបធៀបពីគ្រួសារតូចមួយមកគ្រួសារធំ រហូតដល់ប្រទេសរហូតដល់សកលលោកទៅយើងដឹងហើយ ។

វណ្ណៈ បាទ ។

ស៊ុនៈ បញ្ហាចឹងដើម្បីបញ្ចប់ទុក្ខសោកវិនាសកម្មទាំងអស់នេះ គឺមានតែផ្សះផ្សាជាតិតែម្តង ។

វណ្ណៈ បាទ ។

ស៊ុនៈ រួបរួមជាតិអ៊ីដែលវាហួសវាខុស យើងទុកជាបាបកម្មផ្លូវធម៌ទៅឲ្យវាចប់អស់ទៅហើយរួមគ្នាអភិវឌ្ឍន៍ទៅ ។

វណ្ណៈ បាទ ។

ស៊ុនៈ ដូចជាសម្តេចនាយកលោកមានគោលការណ៍ចឹង តែនេះប្អូនស្រាវជ្រាវនេះជាប្រវត្តិមួយដើម្បីទុកឲ្យក្មេងជំនាន់ក្រោយឲ្យបានដឹង ឲ្យបានយល់ចឹងហើយបានខ្ញុំឯកភាពឆ្លើយសំនួរខ្លះៗដែលបានចង់ចាំ ។

វណ្ណៈ បាទ ។

ស៊ុនៈ ដើម្បីទុកជាប្រវត្តិសាស្ត្រតកូនតចៅ តជីដូនទៅ ។

វណ្ណៈ ចឹងឲ្យក្មេងបានយល់ទៅគ្រាន់ជាបទពិសោធន៍មួយដែរ ថាស្រុកខ្មែរយើងហេតុអីបានជាមានសង្គ្រាមកើតឡើងរវាងខ្មែរនិងខ្មែរ សម្លាប់គ្នាឯងចេះចុះហើយដូចជាប្រទេសជិតខាងដូចជាប្រទេសថៃអីគេ១០០ឆ្នាំគេគ្មានសង្គ្រាមប្រទេសគេជឿនលឿនហើយយើងមានសង្គ្រាមរាប់សិបឆ្នាំមកហើយ ហើយឥឡូវយើងបានធូរស្បើយហើយខ្មែរយើងត្រូវគ្នាអស់ហើយអត់មានបញ្ហាអីទេ តែខ្លាចនៅប្រទេសជិតខាងនៅតែមានចឹង ធ្វើឲ្យសេដ្ឋកិច្ចមិនសូវល្អទេ ចឹងសព្វថ្ងៃយើងនៅជាបញ្ហា ដូចនេះប្រទេសយើងនៅជាប្រទេសអ្នកក្រនៅឡើយទេ ។

ស៊ុនៈ បាទ ។

វណ្ណៈ ប៉ុន្តែខ្ញុំចង់បកទៅសំនួរក្នុងសម័យខ្មែរក្រហមវិញ យើងគ្រាន់តែជាការពិភាក្សាគ្នាខ្ញុំនិងពូទេ យើងថាយួនឈ្លានពានមែននៅឆ្នាំ៧៩ហ្នឹង បើសិនជានិយាយតាមអង្គការសហប្រជាជាតិឬប្រទេសនៅខាងក្រៅគេនិយាយចឹងគេថា កាលហ្នឹងគេថាវាមិនមែនជាការចូលមកដោយព្រមព្រៀងអ្វីមួយ ខាងខ្មែរយើងរត់ទៅប្រាប់ថា ប្រជាជនមានស្លាប់ច្រើនបានពឹងគេឲ្យជួយដល់វៀចូលមកគេថា យួនឈ្លានពាន តែបើយើងគិតមើលបើយើងចាំមើលអង្គការសហប្រជាជាតិមើលឃើញចូលមកជួយ ពូគិតថាប្រជាជនអាចស្លាប់ច្រើនជាងហ្នឹងទៀតឬមួយយ៉ាងម៉េចដែរ ហើយការឈ្លានពានហ្នឹងជាការខុសឬមួយធ្វើឲ្យប្រជាជនយើងបានរស់ដែរ ជាគំនិតរបស់ពូ?

ស៊ុនៈ យើងគិតមើលទៅវាម្យ៉ាងដែរ ឧទាហរណ៍ថា ពេលដែលចូលមកហ្នឹងហើយដែលស្លាប់ តែដល់ម្ខាងទន់ដៃទៅអន្តរាយណ៍ទៅធម្មតាអ្នកនយោបាយគេត្រូវកសាងអភិវឌ្ឍន៍កែប្រែសភាពការណ៍នយោបាយ ។

វណ្ណៈ បាទ ។

ស៊ុនៈ តែរឿងទាំងអស់ហ្នឹងបើយើងគិតទៅខ្មែរសម្លាប់គឺសុទ្ធតែរឿងអ្នកនយោបាយ ។

វណ្ណៈ ចឹងសុទ្ធតែរឿងអ្នកនយោបាយ?

ស៊ុនៈ	សុទ្ធតែរឿងអ្នកនយោបាយ យើងគិតថាម្ខាងចេះម្ខាងចុះអីទៅតែបើមើលគោលការណ៍ប៉ុលពតដែលមានមាគ៌ាហើយ ដល់គាត់អត់បានយកចិត្តទុកដាក់ចុះដល់ភូមិកប្រជាពលរដ្ឋក៏នាំឲ្យប្រជាពលរដ្ឋស្លាប់ដដែល ។

វណ្ណៈ	បាទ ។

ស៊ុនៈ	ដែលគាត់ជាអ្នកដឹកនាំហ្នឹងណាស់ ហើយដល់មើលយួនចូលមក មកជួយសង្គ្រោះហ្នឹងពេលហ្នឹងក៏ស្លាប់ច្រើនដែរ ។

វណ្ណៈ	បាទ ។

ស៊ុនៈ	ពេលហ្នឹងរត់មកតាមផ្លូវអត់មានបាយទឹក ។

វណ្ណៈ	ប៉ុន្តែបើពូគិតថាយួនមិនចូលមកស្លាប់ដែរ?

ស៊ុនៈ	ស្លាប់ច្រើនដែរ មូលហេតុអីទី១បង្អត់បាយ អាមេដឹកនាំហ្នឹងវាចេះតែបង្អត់បាយទៅទី២វាសម្លាប់ដោយអំណាចវា ។

វណ្ណៈ	បាទ ។

ស៊ុនៈ	វាមិនបានគិតដល់សុំយោបល់សួរមតិពីអ្នកណា តុលាការនៅណាមាននោះវាអត់មានវាក៏រិតខ្លួនឯងវាត្រូវស្លាប់គ្រោះថ្នាក់ធំណាស់ ។

វណ្ណៈ	បាទ ។

ស៊ុនៈ	ចឹងទាំងពីរហ្នឹងសុទ្ធតែស្លាប់ដូចគ្នា តែស្លាប់ពេលយួនមកហ្នឹងវាស្លាប់មួយគ្រាំរអស់ប៉ុន្មានៗទៅវាថយវិញទៅ កសាងអភិវឌ្ឍន៍ដោយមានគោលនយោបាយច្បាប់ត្រឹមត្រូវទៅវាមានការរីកចំរើន ។

វណ្ណៈ	បាទ ។

ស៊ុនៈ	តែពេលនោះវាមិនដឹងថា ពេលណារីកចំរើនទេ ។

វណ្ណៈ	បាទ ។

ស៊ុនៈ	យើងមើលអត់ឃើញ ព្រោះមិនយកមាគ៌ាជាច្បាប់អាហ្នឹងខ្ញុំប៉ាន់អត់ត្រូវដែរ តែនេះខ្ញុំឃើញថាតែម្តងហេតុផលវាចឹង ។

វណ្ណៈ	នៅចុងក្រោយនេះ វាគ្រាន់តែពាក្យចាមអារាមក្រោយ៧៩ទេ ដូចជាពាក្យគេនិយាយថា "សម្លាប់ឲ្យអស់ទុកតែស្រីៗប៉ុន្មានទេ ដើម្បីទុកបង្កាត់ជាមួយបុរសចិនណាណីនោះ ពូមានធ្លាប់បានឮទេ? ថាទុកតែខ្មែរប៉ុន្មាននោះ ហ្នឹងជាពាក្យអាចានអារាមទេ ហើយដល់ពេលចុង

ក្រោយទៀតក៏មានរឿងរ៉ាវច្រើនដែលថា តែខាងស្រុកខ្ញុំគេឲ្យជីករណ្ដៅគ្រប់ផ្ទះ គេថាឲ្យជីករណ្ដៅការពារយួនចឹង ។

ស៊ុនៈ ចឹងក្មួយឯងនៅណា?

វណ្ណៈ ខ្ញុំនៅខាងស្រុកកៀនស្វាយ ។

ស៊ុនៈ ជិតទីក្រុងហើយ ។

វណ្ណៈ បាទ! កៀនស្វាយតែណុងគ្រាន់ថាចុងមានស្លាប់៧៨អីហើយទេ មិនជួបលំបាកអីប៉ុន្មានបើគិតទៅ ប៉ុន្តែអ្នកដែលជម្លៀសមកខាងពោធិ៍សាត់អីស្លាប់អស់ច្រើន ដូចខាងគ្រួសារខាងម្ដាយខ្ញុំយាយខ្ញុំអីមកពោធិ៍សាត់ស្លាប់នៅឆ្នាំ៧៧-៧៨មានអ្នកគេនៅរស់ទៅវិញប្រាប់ថានៅសល់ជីដូនមួយខ្ញុំមួយរស់ដល់៧៩ហ្នឹងដែរ តែមិនដឹងជារត់ទៅណាព្រោះគ្នាមិនស្គាល់ផ្លូវទៅផ្ទះវិញណាស់ ព្រោះកាលជម្លៀសមកទើបអាយុមួយខួបពីរខួបចេញពីភ្នំពេញហ្នឹង ចេញពីស្រុកមកមកនៅពោធិសាត់ហើយឪពុកម្ដាយស្លាប់នៅហ្នឹងទាំងអស់ទៅ គេយកទៅវ៉ៃចោល ។

ស៊ុនៈ កាល៧៩ខ្មែរវ៉ៃខ្មែរថា ហួសនិស័យខ្ញុំតែខ្ញុំជួរទ័ពដឹងថាគ្រប់គ្រងទ័ពកាន់អាវុធការពារអត់មានទៅបានដឹងថា គេដល់ថ្នាក់អំណាចអីគេធ្វើដឹងចឹងខ្ញុំដូចជាគិតមិនដល់ដែរ ដូចជាកំរិតយល់ដឹងនៅមានកំរិតតូចដែរ ។

វណ្ណៈ បាទ ។

ស៊ុនៈ មេសហករណ៍អីវ៉ៃទាំងក្រុមវ៉ៃទាំងអី ដូចជានិយាយលែងកើត ។

វណ្ណៈ តែកាលហ្នឹងខ្ញុំដូចជាឆ្ងល់ដែលអ្នកដែលធ្វើការជំនាន់ខ្មែរក្រហមធ្វើធំកាលណាគ្រោះថ្នាក់កាលហ្នឹង ព្រោះខ្ញុំធ្លាប់ចុះសម្ភាសទៅនិយាយទៅហេងអ្នកតូចតាចវិញ ដូចថាយោធាតូចតាចដូចថាមានសំណាងជាង ប្រធានវរៈសេនាធំប្រធានកងពលអនុប្រធានកងពលអី ពួកខ្សែតា ម៉ុកចាប់ពួកហ្នឹង ចាប់ដាក់គុកទួលស្លែងអី?

ស៊ុនៈ កាលហ្នឹងចាប់គ្នាទៅវិញទៅមក ចោទថាខ្សែនេះក្បត់ខ្សែនោះក្បត់អីច្របូកច្របល់មិនដឹងថានយោបាយយ៉ាងម៉េចយើង យើងគិតអត់ដល់ដែរ ។

វណ្ណៈ តែចំពោះខ្ញុំគិតវិញ ខ្ញុំគិតថាសម្លាប់វិលជុំ សម្លាប់វិលជុំខ្ញុំគិតថាស្លាប់អស់តែម្ដងគ្រាន់តែមុននិងក្រោយ ។

ស៊ុនៈ គេសម្លាប់ឯង ឯងសម្លាប់គេ ។

វណ្ណៈ បាទ! ខ្ញុំគិតថាសម្លាប់ឲ្យអស់ គ្រាន់តែមុនក្រោយនេះជាការគិតរបស់ខ្ញុំទេ តែពូគិតមិនដឹងជាយ៉ាងម៉េចទេ ព្រោះអីខ្ញុំស្ដាប់ឌុចនិយាយពេលកាត់ទោសហ្នឹង មេគាត់ វន វ៉េតក៏ត្រូវបាន

សម្លាប់ដែរ សូមទោសបងជាដំបូងហើយគាត់សួរចំលើយតាមរបៀបអន្តការតែម្តង ប្រើពាក្យអញឯង ឯងមានខ្សែអ៊ីអានៅណា ឯងលាក់ខ្សែអីអានៅណា តែមុនសួរចំលើយគាត់បានសុំទោសបង ព្រោះខុចនេះ វ៉ន វេតជាប្រធានគាត់អីចឹង ប្រធានកងពលតាណាតអីចឹង ចឹងពួកហ្នឹងស្លាប់នៅហ្នឹងទាំងអស់ កុយ ធួន ឃើញទេ សម្លាប់តាមតំបន់អីនៅហ្នឹង ចឹងខ្ញុំសូមសួរពូបកទៅក្រោយ៧៩វិញ ។

ស៊ុនៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងក្រោយ៧៩ ហេតុអីបានជាពូរត់មកតាមជាយដែន ពូមិននៅខេត្តដើម្បីជួបជុំបងប្អូនម៉ែឪចឹង?

ស៊ុនៈ ក្នុងនាមខ្មែរពុថា យួនឈ្លានពានហើយ ។

វណ្ណៈ ចឹង?

ស៊ុនៈ បាទ ។

វណ្ណៈ ចឹង៧៩ពូរត់តែម្តង?

ស៊ុនៈ អត់ទេ មានរត់អីទេ កងទ័ពវៃតែម្តង វៃហើយចេះតែថយៗ ថយពីកំពង់ឆ្នាំងមករហូតចឹងទៅ តែវៃទៅចេះតែចាញ់គេ ចេះតែថយទៅ ។

វណ្ណៈ ចឹងចូលមកពូមកនៅខាងណាវិញ?

ស៊ុនៈ នៅខាងខ្មែរក្រហមដដែលហ្នឹង នៅជាប៉ុល ពតដដែល ។

វណ្ណៈ នៅខ្មែរក្រហមហ្នឹងតែពូនៅច្រកណា?

ស៊ុនៈ នៅច្រក៥០២ហ្នឹង ។

វណ្ណៈ ៥០២នៅសំឡូត?

ស៊ុនៈ អត់ទេ ៥០២សំឡូត៥០៥នៅហ្នឹង ។

វណ្ណៈ ចឹងនៅហ្នឹង៥០៥?

ស៊ុនៈ បាទ!៥០៥កងពលទី២ ជួបអស់ហើយគិតទៅមេកងពលហ្នឹង ។

វណ្ណៈ ចឹង៥០៥ពីណាជាអ្នកដឹកនាំ?

ស៊ុនៈ លោករ៉ែនស្លាប់បាត់ហើយ យូរទៅក្បត់ខ្លួនឯងក្បត់ទ័ពមិនដឹងថាស្អី ។

វណ្ណៈ ឈ្មោះ អីរ៉ែន?

ស៊ុនៈ អត់ស្គាល់ទេ កូនប្រសាតា ម៉ុកហ្នឹងតែម្តងដូចជាអត់មានកើតការមួយកូនប្រសារតាម៉ុក ។

វណ្ណៈ បាទ ។

ស៊ុនៈ ឡើងធំដូចជាល្វធំខ្លោ ឡើងទៅដូចជាអំណាចយូរៗទៅស្រីៗអ្នកណាដឹងសម្លាប់អ្នកហ្នឹង ជួរទ័ពអីក៏កើតកុលយុគ ។

វណ្ណៈ ចឹងកាលហ្នឹងពូមានដឹងថា តា ម៉ុក សម្លាប់០៥និង០៦អីនោះ ពូដឹងទេ កាលហ្នឹង?

ស៊ុនៈ អត់ទេ វ៉ែនហ្នឹង គាត់សម្លាប់ចោលតែម្ដងកូនប្រសារគាត់ហ្នឹងយកទៅដើងទៅ ។

វណ្ណៈ ចឹងវ៉ែនហ្នឹងកូនប្រសារតា ម៉ុក តា ម៉ុកសម្លាប់ទៀត?

ស៊ុនៈ ហ្នឹងហើយ ។

វណ្ណៈ ម៉េចបានដឹងថា តា ម៉ុកសម្លាប់?

ស៊ុនៈ ចុះយកទៅដើងទៅ ដូចជាឆ្កួតចឹងដូចជាមនុស្សខួលក្បាលវាអត់ដល់គំរិតម៉េចទេ អត់បានដឹងដល់ចឹងគាត់ឲ្យគេយកសម្លាប់ចោលទៅ មិនដឹងថាស៊ីៗអាចម៍ៗដល់វាឆ្កួតវង្វេងឡប់វាទៅ ។

វណ្ណៈ ចឹងគាត់នៅក្មេងដែរ?

ស៊ុនៈ គាត់ប្រហែលជាបងខ្ញុំខ្ទង់៦០ជាង ។

វណ្ណៈ តែកាលស្លាប់?

ស៊ុនៈ កាលស្លាប់៥០ជាង ។

វណ្ណៈ ចឹងកូនប្រសារគាត់?

ស៊ុនៈ កូនប្រសារតា ម៉ុកហ្នឹងតែម្ដង តែមិនដឹងថាប្ដីប្រពន្ធឆ្កួតឡប់ម៉េចមិនដឹង វង្វេងវង្វាន់ ។

វណ្ណៈ ចឹងគាត់កាន់ទ័ពខាង៥០៥?

ស៊ុនៈ កាន់ខាង៥០៥និង៥០២ខាងសំឡូត ។

វណ្ណៈ ចឹង៥០៥ហ្នឹងនៅខាងពោធិ៍សាត់?

ស៊ុនៈ ពោធិសាត់ កំពង់ឆ្នាំង ។

វណ្ណៈ ចឹងបន្ទាប់ពីឈ្មោះ វ៉ែន មានពីណាទៀតពូ?

ស៊ុនៈ ឈ្មោះ ធី ស្លាប់នៅអូរសោមនេះ ។

វណ្ណៈ ស្លាប់ឥឡូវ?

ស៊ុនៈ ស្លាប់មិនដឹងជាយួនកន្ទ្រាក់មីនអីយ៉ាងម៉េច ស្លាប់កាលជំនាន់សង្គ្រាម ។

វណ្ណៈ ជំនាន់ណា?

ស៊ុនៈ ជំនាន់៨០ជាង ស្លាប់អស់មេកងពលបើនិយាយ និយាយរួមអត់មានសល់ ។

វណ្ណៈ ចឹងមេកងពលក្រោយៗទៀតពូ?

ស៊ុនៈ	អត់ទេ រតេរាយបែកបាកអស់ហើយ ក្រោយមកមានតា មុតហ្នឹងមកគ្រប់គ្រងទាំងខាងនេះ ទាំងណែសទាំងអស់ហ្នឹងតែម្ដង ទាំង៥០២ទាំង៥០៥ ។

វណ្ណៈ	ចឹងតា មុតកូនប្រសារតា ម៉ុកដែរ?

ស៊ុនៈ	កូនប្រសារ តា ម៉ុក ។

វណ្ណៈ	ចឹងវ៉ែនហ្នឹងក៏កូនប្រសារតា ម៉ុក?

ស៊ុនៈ	កូនប្រសារ តា ម៉ុក ។

វណ្ណៈ	ចឹងធីមិនមែនទេ?

ស៊ុនៈ	ធីមិនមែនទេ ។

វណ្ណៈ	ចឹងនៅពេលស្លាប់ធីហើយ តា មុតមកកាន់កាប់វិញ?

ស៊ុនៈ	អត់ទេ ស្លាប់ធីស្លាប់វ៉ែនទៅបានតា មុត ស្លាប់អស់តា គិតមេធំៗមិនមែនដោយវៃគ្នាអីទេ ស្លាប់ដោយអាលីអាឡឺផ្ទេះផ្ដាស់មិនដឹងស៊ីបើតាមខ្ញុំមើល ខ្ញុំមើលទៅឃើញភាពល្ងង់ខ្លៅហ្នឹងតែម្ដងហើយចេះតែមានអំណាច ខ្ញុំបួសរៀនចេះដឹងគេខ្វះប៉ុណ្ណឹងគេក៏គេវាធំហើយរៀនសូត្របន្ថែមវាអត់សូវមានបើនិយាយទៅ មានតែបញ្ហាទ័ពមានតែដែនទី ត្រីវិស័យបញ្ហាកាំភ្លើងធំតូចរៀនចំងាយរៀនវិធីសាស្ត្រប៉ុណ្ណឹង ។

វណ្ណៈ	បាទ!ហើយចុះតា មុតគាត់ជាអ្នកកាន់កាប់ តា មុតគាត់ជាអ្នកកាចអីទេ?

ស៊ុនៈ	កាលពីមុនល្បីថា កាចតែដល់ពេលមកដឹកនាំហ្នឹងអត់មានឮសូវឮថាកាចទេ ។

វណ្ណៈ	ចឹងក្រោយ៧៩គាត់ដឹកនាំធម្មតា?

ស៊ុនៈ	បាទ!គាត់ដឹកនាំធម្មតា ។

វណ្ណៈ	កាលហ្នឹងទាហានមានប្រាក់ខែដែលឬ?

ស៊ុនៈ	អត់មានទេ ។

វណ្ណៈ	តែអាហារហូបចុកគ្រាប់គ្រាន់មានរបបមានអី?

ស៊ុនៈ	បាទ ។

វណ្ណៈ	កងទ័ពនៅខាងនេះមានច្រើនពាន់នាក់ដែលឬ?

ស៊ុនៈ	មានច្រើនមានច្រើនម៉ឺនច្រើនលាននាក់ ។

វណ្ណៈ	លានយ៉ាងម៉េចឬច្រើនណាស់លាន?

ស៊ុនៈ	ចុះចាប់ពីភ្នំដងរែកមកយើងនិយាយខ្មែរក្រហមណាស់ ។

វណ្ណៈ ហ្នឹងហើយនិយាយតែផ្នែកទ័ព តែយើងចង់និយាយទ័ពនៅផ្នែកនេះទេ តំបន់ពោធិសាត់និងកំពង់ឆ្នាំងនេះ?

ស៊ុនៈ ៧ទៅ៨ពាន់ ចុះមួយអនុសេនាតូចអនុសេនាធំពេញៗ ដូចខ្ញុំមួយអនុសេនាតូចមាន៩៨០នាក់មួយផ្លូវ៥៦ដល់ពោធិ៍សាត់ហ្នឹងមួយវរៈ ។

វណ្ណៈ ចឹងកាលហ្នឹងខាងខ្មែរក្រហមមានស្លាប់ច្រើនដែលឬអត់សូវទេ?

ស៊ុនៈ អត់សូវទេ ។

វណ្ណៈ ចឹងវៀតណាម?

ស៊ុនៈ វៀតណាមមានច្រើន ។

វណ្ណៈ ចឹងវៀតណាមស្លាប់ច្រើន?

ស៊ុនៈ បាទ ។

វណ្ណៈ កន្លែងណាក៏ពូចឹងដែរ ព្រោះអីពូថាខ្មែរក្រហមមានគ្នាតែ៥នាក់ ហ៊ានវ៉ៃជាមួយវៀតណាម ៥០នាក់?

ស៊ុនៈ ហ្នឹងហើយកន្ទ្រាក់មីនកាលហ្នឹង ខ្ញុំដឹងខ្លួនឯងវ៉ៃមួយកន្លែងនោះទ័ពវាមានប្រហែលជា៣០០នាក់ជាង សឹងថាអត់មានរស់មួយ អាកន្ទ្រាក់មីនហ្នឹង សង្រ្គាមឈ្លបហ្នឹងគឺអត់បានទេ យើងទៅនៅតែ៥នាក់អី ទាញមីន៥ខ្សែនោះ ៥ខ្សែមីនមួយៗបី មួយខ្សែមានបី ។

វណ្ណៈ បាទ ។

ស៊ុនៈ ហើយខ្ញុំប្រវែងខ្សែ១០០ទៅ២០០ម៉ែត្រមនុស្សតែ៥នាក់ទេ យួនស្លាប់ខ្លាំងណាស់យួនស្លាប់មែនទែន ឆ្នាំនោះលែងសម្លាប់ខ្មែរវិញហើយ ពេលហ្នឹងមើលទៅថាអត់ពួកកូបមានតែចាប់ឬបាញ់បង្អើលចោល ហើយជំនាន់"ក៥"អី មានតែបាញ់បង្អើលឲ្យត្រឡប់ទៅវិញ ចុះពីឡានមកការ៉ុងស ស្បោងសពព្រីងពព្រោងចឹងលែងសម្លាប់ហើយ ។

វណ្ណៈ បាទ ។

ស៊ុនៈ ហើយយួនក៏ចាប់យកខ្លះដែរ ចាប់បញ្ជូនទៅដែរ អត់មានទេ ។

វណ្ណៈ ចឹងនៅពេលចាប់បានយួនហ្នឹងបញ្ជូនទៅខាងណាវិញ?

ស៊ុនៈ ទៅខាងក្រោយ ទៅថៃចឹងទៅ មិនដឹងជាទៅណាយើងមិនបានដឹង ។

វណ្ណៈ ចឹងពូថាបញ្ជូនទៅថៃដូរអង្គរមកវិញ?

ស៊ុនៈ អត់ទេ អង្គរមានខ្លះអី អង្គការសហប្រជាជាតិគេគាំទ្រនោះ ។

វណ្ណៈ ចឹងមានចិនជួយដែរ?

ស៊ុនៈ ចិនអីហ្នឹងនិយាយរួមទាំងអស់ទាំងថៃក៏ជួយដែរ ពេលហ្នឹងមិនប៉ុល ពតស្របច្បាប់ហ៊ុន សែន មិនឈ្មោនពាន ។

វណ្ណៈ ហ្នឹងហើយ ។

ស៊ុនៈ ដល់ប្រជុំប៉ារីទៅដល់សម្របសម្រួលគ្នាទៅបានដកកងទ័ពយួនចេញទៅ អាហ្នឹងផ្សះផ្សាចតុភាគី ។

វណ្ណៈ បាទ ។

ស៊ុនៈ ដល់ចតុភាគីបានខៀវ សំផនបានរដ្ឋប្រហារវ៉ៃខៀវ សំផនអីបានរត់មកវិញបានវ៉ៃបកមួយសារទៀតទៅជាពួកខ្ទាមវិញហើយ ខ្មែរក្រហមបានជាពួកខ្ទាមហើយ គេយកអាឃ្លាំងគ្រាប់នៅថៃ១០គីឡូបួនជ្រុងហ្នឹងទៅហ្នឹងបណ្តោយចេះតែរលាយខ្លួនបន្តិចៗទៅចុះមេនិមួយៗគេមើលសភាពការណ៍ទៅវាអត់គួរជោគជ័យ ។

វណ្ណៈ បាទ ។

ស៊ុនៈ ហើយមកលេងវ៉ៃសាថ្មីវាអត់មានស្មារតី ពេលគេចូលទៅគេដឹងអស់ហើយចឹងគេរំលាយខ្លួនគេតែម្តង ចឹងណានៅរឹងចេះតែរឹងទៅ ហើយខ្ញុំវិភាគគ្រាន់តែឃើញមកវ៉ៃវិញខ្ញុំថាអត់មានទេភាពឈ្នះគ្មានទេ ព្រោះភាពសម្របសម្រួលវាទៅហើយ ស្រាប់តែមកវ៉ៃវិញវាអត់មានសំអាង មានអីសំអាង ។

វណ្ណៈ ចឹងកាលហ្នឹងតា ខៀវ សំផន តា អៀង សារី តា ប៉ុល ពត តា សុន សេនអីមានដែលចុះមកខាងហ្នឹងទេ?

ស៊ុនៈ អត់ទេ អត់ដែលទៅឃើញមានទេ ឃើញដល់ពេលសមាហរណ៍កម្មចតុភាគីហ្នឹងរៀបចំកំលាំងចូលក្នុងហ្នឹង ខ្ញុំក៏អត់បានជួបដែរ តា ម៉ុកអីមកខ្ញុំក៏មិនបានជួបដែរ ។

វណ្ណៈ ចឹងសង្គ្រាមពី៧៩ដល់ឆ្នាំ៨០ជាង ៨៧អីសង្គ្រាមវ៉ៃតាំងខ្មែរសហការជាមួយវៀតណាម វ៉ៃខ្មែរក្រហមអីហ្នឹងកាលនៅសង្គ្រាមខ្លាំងពុះពោល ចុះនៅពេលវៀតណាមដកចេញទៅវិញនេះនៅសល់ខ្មែរនិងខ្មែរសង្គ្រាមនិងថបថយឬនៅតែខ្លាំងដដែលពេលហ្នឹង?

ស៊ុនៈ ថបថយ ទី១ចេះពេលវៀតណាមរំលាយខ្លួនទៅខ្មែរនិងខ្មែរចេះតែស្គាល់គ្នាចុះ ដល់ហើយចេះសម្របសម្រួលគ្នាទៅចេះតែត្រូវគ្នាទៅ ។

វណ្ណៈ បាទ ។

ស៊ុនៈ កាលហ្នឹងរដ្ឋាភិបាលមិនទាន់មានគោលការណ៍យើងនេះត្រូវគ្នាឯង វាចឹងដូចថាអាចម្យ៉ាងហើយស្ងាប់ហ្នឹងទុកមេដឹកនាំថាឲ្យនៅវ៉ៃក៏ដោយគឺបញ្ចប់តែម្តង គិតថាអត់វ៉ៃឈប់តែម្តងជា

ទស្សនៈមួយៗ ដែលក្តាប់បានគឺចិនទាំងគេទាំងខ្ញុំថាឲ្យវៀតកំអត់វៀតដែរ ដូចថាអ៊ីដែលរួបរួមជាតិហើយ អ៊ីដែលវៀតឲ្យនាប់ក្នាងឯងទៀតមិនដឹងជាវៀតធ្វើស្អី ។

វណ្ណៈ បាទ ។

ស៊ុនៈ បទេសយើងគិតជំនាន់អាមេរិចគិតថា វៀតជាមួយអាមេរិចលន់ នល់ដែលខ្មែរយើង ដល់វៀតជាមួយយួនក៏ខ្មែរដែរ ដល់យួនគេដកថយរំលាយខ្លួនចេញពីដូវទ័ពទៅទឹកចិត្តសង្គ្រាមហ្នឹងវាអស់ទឹកចិត្តរៀងខ្លួនតែម្តង ។

វណ្ណៈ ចឹងពូគិតថាថៃមានផលប្រយោជន៍អីដែលបានជាជួយខាងខ្មែរក្រហមកាលហ្នឹង?

ស៊ុនៈ ថៃបានទាំងអស់ស្រូបយកទាំងអស់ ស្រូបទី១ព្រៃឈើពេលសង្គ្រាមយើងលក់ព្រៃឈើឲ្យថៃ ហើយស្រូបទី២សេដ្ឋកិច្ចយើងគ្រប់ផ្នែកដូចជាធ្វើត្បូងស្អីក៏ដោយ សុទ្ធតែគ្រឿងចក្រពីថៃទាំងអស់ ចឹងថៃវាបានប្រយោជន៍ទាំងអស់តែម្តង ។

វណ្ណៈ បាទ ។

ស៊ុនៈ ខ្មែរទៅស៊ីធូរេនសាវម៉ាវអស់តែកន្លះចំការតែវាវាយការណ៍អស់មួយចំការទៅ ។

វណ្ណៈ បាទ ។

ស៊ុនៈ សងវារាប់ម៉ឺន ឧទាហណ៍វាលក់បានតែមួយលានបាត ឧទាហណ៍ដល់ពេលយើងទៅស៊ីទៅបេះយករបស់វា វាថាមួយលានកន្លះទៅពីរលានក៏យើងនៅតែសង ។

វណ្ណៈ បាទ ។

ស៊ុនៈ អាហ្នឹងយើងឃើញហេតុផលហ្នឹង ហើយទិញសម្ភារអ៊ីៗពីវាទាំងអស់វាចំណេញគ្រប់ផ្នែកចឹងដល់ខ្មែរត្រូវគ្នាវាមិនសូវឲ្យសេចក្តីសុខមកយើងវិញទេ ។

វណ្ណៈ វាគិតថាខាតប្រយោជន៍វាវិញ?

ស៊ុនៈ ថៃវាពូកែបង្វៀសណាស់រឿងសង្គ្រាម តែឥឡូវហ្នឹងខ្លួនវាមិនដឹងវារកវិធីដោះយ៉ាងម៉េច ។

វណ្ណៈ បាទ!ឥឡូវវារីកវដែរ?

ស៊ុនៈ វារីកវដែរ ។

វណ្ណៈ ចឹងយើងបានសុខម្តង?

ស៊ុនៈ បាទ ។

វណ្ណៈ តែយើងក៏មិនទាន់បានសុខដែលហ្នឹង វាធ្វើបាបយើងដែលហ្នឹង វាមិនឲ្យយើងសុខដែលទេ?

ស៊ុនៈ ពូដូចជាប្រញាប់ការងារដែរ ។

វណ្ណៈ ចឹងខ្ញុំអរគុណពូច្រើនដែលបានផ្តល់បទសម្ភាសឲ្យខ្ញុំពូណាស់ ។

ស៊ុនៈ	បាទ ។

វណ្ណៈ	តែខ្ញុំចង់បន្តតែបន្តិចទេ នៅហ្នឹងយើងសមាហរណ៍កម្មនៅឆ្នាំណាពូ?

ស៊ុនៈ	ឆ្នាំ៩៧-៩៨ហ្នឹង ។

វណ្ណៈ	ចឹងពីគិតមើលថា ការសម័យតស៊ូនិងសម័យឥឡូវនេះវាលក្ខណៈខុសគ្នាយ៉ាងម៉េចឥឡូវស្រួលជាងមុនឬកាលពីមុនស្រួលជាង តាមគំនិតរបស់ពូ?

ស៊ុនៈ	យើងមិននិយាយក៏ដូចជាក្មួយៗមកដែរ ពីដើមមានមកអីដល់នេះបានទេ មកត្រឹមតែខេត្តពោធិ៍សាត់ទេ ។

វណ្ណៈ	បាទ ។

ស៊ុនៈ	យើងឃើញប៉ុណ្ណឹងហើយ ឥឡូវផ្លូវល្អិងល្អើយមានទូរសព្ទ័ទាក់ទងគ្នាបានទាំងអស់ មានមណ្ឌលសុខភាពសាលារៀនមានគ្រប់ភូមិគ្រប់ស្រុកអានេះយើងមិនបាច់រៀបរាប់អីច្រើនទេ យើងឃើញជាក់ស្ដែងដូចខ្ញុំនិយាយខាងដើមខ្លះចឹង ។

វណ្ណៈ	ចឹងប្រជាជននៅនេះគេប្រកបមុខរបរអីភាគច្រើន?

ស៊ុនៈ	ស្រុកមានតែចំការស្រែខ្លះមានដីស្រែធ្វើស្រែ ខ្លះមានដីចំការធ្វើចំការ ។

វណ្ណៈ	ចឹងខ្ញុំអរគុណពូច្រើនហើយ ។

ស៊ុនៈ	បាទ ។

**ចប់**